ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ......សហវ.ប្រក

# ប្រកាស
# ស្តីពី
# បែបបទ និងនីតិវិធីនៃការបង់ភាគលាភរបស់សហគ្រាសសាធារណៈ និងក្រុមហ៊ុនចម្រុះ ដែលរដ្ឋមានភាគកម្មសាធារណៈជាចំនួនភាគតិច

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៧១ អនក្រ.បក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១ ស្តីពីការបំពេញបន្ថែមអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងធានាប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព និងគណនេយ្យភាព នៃការគ្រប់គ្រងការប្រមូលចំណូល និងការបង់ភាគលាភរបស់សហគ្រាសសាធារណៈ និងក្រុមហ៊ុនចម្រុះដែលរដ្ឋមានភាគកម្មសាធារណៈជាចំនួនភាគតិច។

**ប្រការ២.-**

ប្រកាសនេះ មានគោលដៅកំណត់អំពីវិធាន បែបបទ និងនីតិវិធីនៃការប្រមូលចំណូល និងការបង់ភាគលាភរបស់សហគ្រាសសាធារណៈ និងក្រុមហ៊ុនចម្រុះដែលរដ្ឋមានភាគកម្មសាធារណៈជាចំនួនភាគតិច។

**ប្រការ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះសហគ្រាសសាធារណៈ និងក្រុមហ៊ុនចម្រុះដែលរដ្ឋមានភាគកម្មសាធារណៈជាចំនួនភាគតិច។

**ប្រការ៤.-**

និយមន័យនៃបច្ចេកស័ព្ទប្រើប្រាស់ក្នុងក្របខ័ណ្ឌនៃប្រកាសនេះ ត្រូវបានកំណត់ដូចខាងក្រោម÷

- **ភាគលាភ** សំដៅដល់ចំណែកទឹកប្រាក់ដែលបានពីការបែងចែកប្រាក់ចំណេញរបស់សហគ្រាសសាធារណៈ និងក្រុមហ៊ុនចម្រុះដែលរដ្ឋមានភាគកម្មសាធារណៈជាចំនួនភាគតិច ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។
- **សហគ្រាសសាធារណៈ** សំដៅដល់សហគ្រាស ដែលមានដើមទុនទាំងអស់ ឬ ភាគច្រើនជារបស់រដ្ឋ។
- **ភាគកម្មសាធារណៈ** សំដៅដល់ចំណែកនៃដើមទុនរបស់ក្រុមហ៊ុនចម្រុះ ដែលកាន់កាប់ដោយរដ្ឋ ដោយគ្រឹះស្ថានសាធារណៈ ឬ ដោយក្រុមហ៊ុនរដ្ឋ។ កាលណាភាគកម្មសាធារណៈលើសពី៥១% (ហាសិបមួយភាគរយ)នៃដើមទុន ឬ សិទ្ធិបោះឆ្នោត ក្រុមហ៊ុនចម្រុះត្រូវបានចាត់ទុកជាសហគ្រាសសាធារណៈ។

- ក្រុមហ៊ុនចម្រុះដែលរដ្ឋមានភាគកម្មសាធារណៈជាចំនួនភាគតិច សំដៅដល់ក្រុមហ៊ុនចម្រុះ ដែលរដ្ឋ ឬ ភាគីរដ្ឋមានភាគកម្មសាធារណៈជាចំនួនភាគតិច ឬ មានសិទ្ធិបោះឆ្នោតក្នុងក្រុមហ៊ុន ចម្រុះតិចជាង ៥០%(ហាសិបភាគរយ)។
- ប្រាក់ចំណេញសុទ្ធ សំដៅដល់ប្រាក់ចំណេញក្រោយបង់ពន្ធ ដែលត្រូវកំណត់យកប្រាក់ចំណេញមុនបង់ពន្ធដកពន្ធលើប្រាក់ចំណូល។

## ជំពូកទី២
## នីតិវិធីនៃការកំណត់ និងការបង់ភាគលាភរបស់សហគ្រាសសាធារណៈ និងក្រុមហ៊ុនចម្រុះ ដែលរដ្ឋមានភាគកម្មសាធារណៈជាចំនួនភាគតិច

**ប្រការ៥.-**

ការកំណត់បែងចែកភាគលាភរបស់សហគ្រាសសាធារណៈដែលរដ្ឋមានដើមទុន១០០% ត្រូវអនុវត្តស្របតាមអត្រាកំណត់គិតជាភាគរយនៃប្រាក់ចំណេញសុទ្ធ ដែលមានចែងក្នុងលក្ខន្តិកៈសហគ្រាស អនុក្រឹត្យបង្កើតសហគ្រាស ឬ លិខិតបទដ្ឋានគតិយុត្តជាធរមាន បន្ទាប់ពីក្រុមប្រឹក្សាភិបាលបានពិនិត្យនិងអនុម័តលើតុល្យការ និងគណនីលទ្ធផលនៃការិយបរិច្ឆេទ។

ក្នុងករណីពុំមានចែងអំពីអត្រាកំណត់គិតជាភាគរយនៃប្រាក់ចំណេញសុទ្ធក្នុងលិខិតបទដ្ឋានគតិយុត្ត ដូចមានចែងក្នុងវាក្យខណ្ឌខាងលើនៃប្រការ៥នេះ សហគ្រាសសាធារណៈនោះ ត្រូវមានកាតព្វកិច្ចបែងចែកភាគលាភចូលថវិការដ្ឋយ៉ាងតិចចំនួន ១០%(ដប់ភាគរយ)នៃប្រាក់ចំណេញសុទ្ធ បន្ទាប់ពីក្រុមប្រឹក្សាភិបាលបានពិនិត្យនិងអនុម័ត លើតុល្យការ និងគណនីលទ្ធផលនៃការិយបរិច្ឆេទ។

ដោយឡែក ចំពោះការកំណត់បែងចែកភាគលាភរបស់÷

- ក្រុមហ៊ុនចម្រុះជាសហគ្រាសសាធារណៈ ត្រូវអនុវត្តការបែងចែកភាគលាភតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល ស្របតាមអនុក្រឹត្យបង្កើត ឬ តាមលក្ខន្តិកៈក្រុមហ៊ុន
- ក្រុមហ៊ុនចម្រុះដែលរដ្ឋមានភាគកម្មសាធារណៈជាចំនួនភាគតិចត្រូវអនុវត្តស្របតាមលក្ខន្តិកៈក្រុមហ៊ុន។

**ប្រការ៦.-**

សហគ្រាសសាធារណៈបោះផ្សាយលក់មូលបត្រជាសាធារណៈ ត្រូវកំណត់ការបែងចែកភាគលាភស្របទៅតាមលក្ខន្តិកៈ និងលិខិតបទដ្ឋានគតិយុត្តនៃសហគ្រាសបោះផ្សាយលក់មូលបត្រជាសាធារណៈ។

**ប្រការ៧.-**

ការបង់ភាគលាភចូលថវិការដ្ឋរបស់សហគ្រាសសាធារណៈ និងក្រុមហ៊ុនចម្រុះដែលរដ្ឋមានភាគកម្មសាធារណៈជាចំនួនភាគតិច ត្រូវកំណត់ដូចខាងក្រោម÷

- អង្គភាព រួមមានសហគ្រាសសាធារណៈបោះផ្សាយលក់មូលបត្រជាសាធារណៈ ក្រុមហ៊ុនចម្រុះជាសហគ្រាសសាធារណៈ និងក្រុមហ៊ុនចម្រុះដែលរដ្ឋមានភាគកម្មសាធារណៈជាចំនួនភាគតិច ត្រូវបង់ចំណែកភាគលាភ ដែលភាគីរដ្ឋត្រូវទទួលបានទាំងអស់ តែក្នុងមួយលើកនៃការិយបរិច្ឆេទបែងចែកភាគលាភនីមួយៗ ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល ព្រមទាំងស្របតាមគោលការណ៍កំណត់នៃលិខិតបទដ្ឋានគតិយុត្តរបស់អង្គភាពទាំងនេះ។
- ចំពោះសហគ្រាសសាធារណៈផ្សេងទៀត ត្រូវបង់ភាគលាភតាមចំណែកដែលភាគីរដ្ឋត្រូវទទួលបានមិនឱ្យហួសពីដំណាច់ត្រីមាសទី២នៃឆ្នាំការិយបរិច្ឆេទបន្ទាប់។
- ក្នុងករណីខកខានមិនបានបង់តាមការកំណត់ខាងលើនេះសហគ្រាសសាធារណៈ និងក្រុមហ៊ុនចម្រុះដែលរដ្ឋមានភាគកម្មសាធារណៈជាចំនួនភាគតិច ត្រូវប្រឈមនឹងការដាក់ពិន័យ ២% (ពីរភាគរយ) ក្នុងមួយខែនៃចំនួនទឹកប្រាក់ភាគលាភដែលត្រូវបង់ជូនភាគីរដ្ឋ ស្របតាមលិខិតបទដ្ឋានគតិយុត្ត ដែលបានកំណត់ជាធរមាន។

**ប្រការ៨.-**

សហគ្រាសសាធារណៈ និងក្រុមហ៊ុនចម្រុះដែលរដ្ឋមានភាគកម្មសាធារណៈជាចំនួនភាគតិច ត្រូវបង់ភាគលាភចូលក្នុងថវិការដ្ឋតាមនីតិវិធីដូចខាងក្រោម÷

- ត្រូវបង់ភាគលាភចូលក្នុងគណនីទោលរបស់រតនាគារជាតិនៅធនាគារជាតិនៃកម្ពុជា ឬ តាមរយៈធនាគារដៃគូ ឬនិងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូ ហើយត្រូវបញ្ជូនបណ្ណបង់ប្រាក់ ឬ ប្រកាសឥណពន្ធទៅក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស
- បន្ទាប់ពីទទួលបានបណ្ណបង់ប្រាក់ ឬ ប្រកាសឥណពន្ធ ក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេសត្រូវធ្វើសលាកបត្របង់ចំណូលតាមប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) និងផ្ញើសលាកបត្របង់ចំណូលនោះទៅអគ្គនាយកដ្ឋានរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

នីតិវិធីនៃការកត់ត្រាចំណូលពីភាគលាភទៅក្នុងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) ត្រូវអនុវត្តតាមសារាចរណែនាំស្តីពី ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។

**ប្រការ៩.-**

តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងក្រុមប្រឹក្សាភិបាលនៃសហគ្រាសសាធារណៈ និងមន្ត្រីត្រួតពិនិត្យរដ្ឋត្រូវជំរុញ និងតាមដានការបង់ភាគលាភដែលជាចំណែករបស់ភាគីរដ្ឋ ចូលក្នុងថវិការដ្ឋឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា។

សមាជិកក្រុមប្រឹក្សាភិបាលតំណាងឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃក្រុមហ៊ុនចម្រុះដែលរដ្ឋមានភាគកម្មសាធារណៈជាចំនួនភាគតិច ត្រូវជំរុញ និងតាមដានការបង់ភាគលាភដែលជាចំណែករបស់ភាគីរដ្ឋចូលក្នុងថវិការដ្ឋឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា ព្រមទាំងត្រូវផ្ដល់របាយការណ៍ស្ដីពីស្ថានភាពបម្រែបម្រួលមូលធនចំនួនភាគហ៊ុននិងភាគហ៊ុនគិតជាសាច់ប្រាក់នៃចំណែករបស់ភាគីរដ្ឋមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ចម្លងជូនមកអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ) បន្ទាប់ពីក្រុមប្រឹក្សាភិបាលពិនិត្យនិងអនុម័ត លើតុល្យការ និងគណនីលទ្ធផលនៃការិយបរិច្ឆេទ។

## ជំពូកទី៣

## អវសានប្បញ្ញត្តិ

**ប្រការ១០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១១.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានអគ្គនាយក អគ្គនាយក នាយកនៃសហគ្រាសសាធារណៈ និងក្រុមហ៊ុនចម្រុះដែលភាគីរដ្ឋមានភាគកម្មសាធារណៈជាចំនួនភាគតិច ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៧រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ÷**

- -ទីស្ដីការគណៈរដ្ឋមន្ត្រី
- -ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- -គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- -ដូចប្រការ ១១
- -រាជកិច្ច
- -ឯកសារ កាលប្បវត្តិ